# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ប្រព័ន្ធសិក្សាលេខ១

សាលាបឋមសិក្សា ឃើគប្រាយ (Kirkbride)
1501 South 7th Street
Philadelphia, Pennsylvania 19147
ទូរស័ព្ទ៖ ២១៥-៩៥២-៦២១៤   ទូរសារ៖ ២១៥-៩៥២-៦២៥៣

## ទំព័រនៃព័ត៌មានសំខាន់ៗ - ការរួមបញ្ចូលថ្នាក់ដែលមានកម្រិតខុសគ្នា

**តើការរួមបញ្ចូលថ្នាក់ដែលមានកម្រិតខុសគ្នា ដូចម្តេចទៅ?**

គឺជាការអនុវត្តន៍នៃការបង្កើតថ្នាក់ដែលមានសិស្សមានកម្រិតថ្នាក់ពីរខុសគ្នា-ឧទាហរណ៍ ថ្នាក់ទី២ និង ថ្នាក់ទី៣។ ថ្នាក់ទាំងនេះ ជួនកាលហៅថា « split grades (ថ្នាក់បំបែក)» ឬ «multi-age classes (ថ្នាក់ដែលមានសិស្សអាយុខុសៗគ្នា)» (ភាគច្រើន ថ្នាក់ដែលមានសិស្សអាយុខុសៗគ្នា រួមបញ្ចូលលើសពីពីរថ្នាក់ ខុសៗគ្នា)។

**ហេតុអ្វីបានជាមានថ្នាក់បែបនេះ?**

នាយកសាលារៀបចំឲ្យមានថ្នាក់រួមបញ្ចូលគ្នានៅពេលណាចំនួនសិស្សគ្មានតុល្យភាពនិងចំនួនគ្រូ ហើយផ្តល់ឱកាសបន្ថែមទៀតក្នុងការចាត់តាំងសិស្ស។ ឧទាហរណ៍ មានសិស្សថ្នាក់ទី៣ ចំនួន២៩នាក់ ថ្នាក់ទី៤ ចំនួន១១នាក់។ នៅពេលគណកម្មការផ្នែកចាត់ចែងបុគ្គលិកប្រឈមមុខនឹងចំនួនដែលមិនស្មើគ្នានេះ គេអាចប្រើការរួមបញ្ចូលថ្នាក់ ដើម្បីឲ្យមានតុល្យភាព និងឲ្យត្រូវតាមការកំណត់នៃទំហំថ្នាក់ ហើយធ្វើឲ្យមានឱកាសចាត់តាំងលើសពីមួយ សម្រាប់ថ្នាក់នីមួយៗ។ ការបង្កើតថ្នាក់ធ្វើឡើងយ៉ាងប្រុងប្រយ័ត្ន ដោយបុគ្គលិករបស់សាលា។ ទោះជាសាលាត្រូវធ្វើតាមការកំណត់ផ្សេងៗ សិស្សទាំងអស់ត្រូវបានគេចាត់តាំងទៅតាមការពិចារណាលើចំណុចលក្ខណៈទាំងអស់របស់សិស្សម្នាក់ៗ។ ដូចគ្នានេះដែរ សេចក្តីត្រូវការរបស់សិស្សម្នាក់ៗក៏ត្រូវមានតុល្យភាពជាមួយនឹងសក្តានុពល សេចក្តីត្រូវការ និងភាពចុះសម្រុងគ្នា របស់ក្រុម។ កត្តាផ្សេងៗខ្លះទៀតដែលគេយកមកពិចារណាគឺ គ្រូ ទំហំថ្នាក់ ភេទ ទម្លាប់ធ្វើកិច្ចការ ការបណ្តុះអារម្មណ៍ សេចក្តីត្រូវការនៃការអប់រំពិសេស ការអភិវឌ្ឍន៍ផ្នែកភាសាអង់គ្លេស កម្រិតថ្នាក់ដែលកំពុងបង្រៀន ។ល។

**តើពិតជាអាចបង្រៀនកម្រិតថ្នាក់ពីរខុសគ្នា បានដែរឬទេ?**

ដូចគ្នានឹងថ្នាក់ដែលមានសិស្សមានកម្រិតថ្នាក់ស្មើគ្នាដែរ គ្រូបង្រៀននៅក្នុងថ្នាក់រួមបញ្ចូលគ្នា ប្រើវិធីបង្រៀនដ៏ទូលំទូលាយ ដើម្បីធ្វើយ៉ាងណាឲ្យពួកគាត់អាចបង្រៀនទៅតាមសេចក្តីតម្រូវនៃកម្មវិធីសិក្សាទាំងអស់។ សិស្សានុ

សិស្សដែលរៀននៅក្នុងថ្នាក់រួមបញ្ចូលគ្នា ធ្វើតាមការចង់បាននៃកម្រិតថ្នាក់នីមួយៗរបស់ពួកគេ។ សិស្សានុសិស្ស ដែលរៀននៅក្នុងថ្នាក់រួមបញ្ចូលគ្នា ចំណាយពេលសិក្សាជាមួយថ្នាក់ទាំងមូល តាមក្រុមតូចៗ និង សិក្សាដោយ ឡែកៗ រៀងៗខ្លួន។ ជួនកាល គ្រូដាក់ពួកគេជាក្រុមដោយយោងទៅលើកិច្ចការអ្វីមួយ ហើយពេលខ្លះទៀតគ្រូ បែងចែកពួកគេជាក្រុមដោយយោងទៅលើសេចក្តីត្រូវការនៃការសិក្សារបស់ពួកគេ។ នេះជាឧទាហរណ៍ខ្លះៗ ដែលគ្រូនៅថ្នាក់រួមបញ្ចូលគ្នា បង្រៀនទៅតាមកម្មវិធីសិក្សាសម្រាប់ថ្នាក់ពីរខុសគ្នា។

ការចង់បានទូទៅជាច្រើនផ្នែកនៃកម្មវិធីសិក្សា មិនផ្លាស់ប្តូរពីមួយថ្នាក់ទៅមួយថ្នាក់ទេ ផ្ទុយទៅវិញ ចំណេះដឹងត្រូវ បានគេបង្រៀនទៅតាមរបៀបនៃកម្រិតខុសប្លែកៗពីគ្នា។ នៅក្នុងថ្នាក់រួមបញ្ចូលគ្នា ថ្នាក់ទី១ និងថ្នាក់ទី២ សិស្ស ទាំងអស់ត្រូវសិក្សាអំពី វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា។ សិស្សថ្នាក់ទី១ ប្រហែលជាស៊ើបអង្កេតអំពីរបៀបនៃការ សម្របទៅតាមបរិស្ថាន និង/ឬ ប្រតិកម្មទៅនឹងការផ្លាស់ប្តូរនៃបរិស្ថាន របស់រុក្ខជាតិផ្សេងៗ។ ចំពោះកិច្ចការដែល គ្រូឲ្យសរសេរ ថ្នាក់ទី១ត្រូវប្រើពាក្យបញ្ចូលគ្នាដើម្បីសរសេរឃ្លាសាមញ្ញៗ។ សិស្សថ្នាក់ទី២ ដែលរៀនអំពីចំណេះ វិទ្យាសាស្ត្រ នឹងរៀនពន្យល់អំពីទីកន្លែងដែល រុក្ខជាតិ និង សត្វ ត្រូវការសម្រាប់ការរស់នៅរបស់ពួកវា (ឧ. ចំណី ទឹក ខ្យល់ បរិវេណ និង ពន្លឺ)។ ចំពោះកិច្ចការដែលត្រូវសរសេរ សិស្សថ្នាក់ទី២ត្រូវគ្រូតម្រូវឲ្យប្រើឃ្លាដែលមាន ប្រវែង និង កម្រិត ខុសៗគ្នា។ គ្រូនឹង ពិនិត្យ និង វាយតម្លៃ កិច្ចការខុសពីគ្នា ដើម្បីឲ្យត្រូវតាមការចង់បាននៃកម្មវិធី សិក្សាដែលខុសគ្នាបន្តិចបន្តួច ពីថ្នាក់មួយ ទៅថ្នាក់មួយទៀត។

**នេះជាឧទាហរណ៍មួយផ្សេងទៀត៖**

គ្រូអាចឲ្យសិស្សក្នុងថ្នាក់ទាំងអស់ចូលរួមក្នុងសកម្មភាពរួម បន្ទាប់មកចាប់ផ្តើមធ្វើកិច្ចការដោយឡែកៗ រៀងៗខ្លួន ឬ ជាក្រុមតូចៗ ទៅតាមកម្មវិធីសិក្សាដែលគេចង់បាននៃកម្រិតថ្នាក់នីមួយៗ។ ឧទាហរណ៍នៅក្នុងថ្នាក់រួមបញ្ចូល គ្នា ថ្នាក់ទី១ និង ថ្នាក់ទី២ នៅពេលបង្រៀនវិទ្យាសាស្ត្រនៃប្រព័ន្ធជីវិត គ្រូអាចចាប់ផ្តើមដោយបញ្ចាំងវីដេអូអំពី សត្វអ្វីមួយ។ សិស្សថ្នាក់ទី១ នឹងធ្វើកិច្ចការ ដើម្បីបញ្ជាក់ពីលក្ខណៈ និង សេចក្តីត្រូវការ នៃអ្វីៗដែលមានជីវិត ក្នុងខណៈដែលសិស្សថ្នាក់ទី២ ស្វែងយល់ និង រៀបរាប់ ពីលក្ខណៈដែលស្រដៀងគ្នាក្នុងចំណោមសត្វផ្សេងៗ និង ការផ្តោតទៅលើ ការលូតលាស់ និង ការផ្លាស់ប្តូរ របស់សត្វទាំងនោះ។

ក្នុងកំឡុងពេលរៀនអក្សរសាស្ត្រ សិស្សត្រូវគ្រូបង្រៀនដោយឡែកៗពីគ្នា និងទៅតាមក្រុមដែលបានរៀបចំទុក ដោយប្រុងប្រយ័ត្ន ទៅតាមកម្រិតថ្នាក់របស់ពួកគេ។

ការបង្រៀនគណិតវិទ្យាអាចចាប់ផ្តើមសកម្មភាពជាក្រុមធំ ប៉ុន្តែសិស្សត្រូវគេបែងចែកជាក្រុមទៅតាមកម្រិតថ្នាក់។

**ចំណុចសំខាន់ផ្សេងទៀត៖**

សិស្សនឹងទទួលជំនួយពីគ្រូទីពីរ ដែលចុះជាប់បង្រៀនយ៉ាងជិតដិតនៅក្នុងថ្នាក់ ជារៀងរាល់ថ្ងៃ។ កូនលោកអ្នក នឹងទទួលអត្ថប្រយោជន៍ពីការបង្រៀនយ៉ាងជិតដល់ដោយគ្រូពីរនាក់ ជារៀងរាល់ថ្ងៃ។

### ប៉ុន្តែកូនខ្ញុំនៅក្នុងថ្នាក់ក្មេងដែលមានអាយុច្រើន...តើនឹងមានភាពលំបាកដល់កូនខ្ញុំឬទេ?

មាន! កូនលោកអ្នកនឹងត្រូវប្រឈមមុខនឹងការលំបាកទៅតាមកម្រិតថ្នាក់របស់ពួកគេ។ វាជាការទទួលខុសត្រូវរបស់ គ្រូ និង នាយកសាលា ដែលជាអ្នកអប់រំ ដើម្បីផ្តល់ឲ្យកូនលោកអ្នកនូវកិច្ចការដែលលំបាក ប៉ុន្តែមិនមែនជាកម្មវិធីដែលធ្វើឲ្យមួហ្មងនោះទេ។ នៅពេលដែលប្រធានបទខ្លះដែលកូនលោកអ្នកសិក្សាខុសគ្នាពីក្មេងឯទៀតនៅសាលា នៅពេលខ្លះ សិស្សានុសិស្សទាំងអស់នឹងទទួលកម្មវិធីពេញលេញ និង សព្វគ្រប់ ទៅតាមកម្រិតថ្នាក់។ ជាមួយនឹងការសិក្សាវិជ្ជាទូទៅ កូនលោកអ្នកក៏រៀនធ្វើអ្វីៗជាមួយសិស្សដែលមានអាយុតិចជាងខ្លួន ពង្រឹងទំនុកទុកចិត្តរបស់ពួកគេ ឯករាជ្យភាព និង ចំណេះដឹងក្នុងការដឹកនាំ របស់ពួកគេ។ តាមពិត ការស្រាវជ្រាវបានឲ្យដឹងថា អ្វីៗទាំងនេះគឺជាអត្ថប្រយោជន៍ដ៏សំខាន់បំផុត។

### កូនខ្ញុំនៅក្នុងថ្នាក់ក្មេងដែលមានអាយុតិច...តើពួកគេនឹង មានការច្របូកច្របល់/ទទួលអ្វីៗច្រើនលើសលប់/មិនទទួលការយកចិត្តទុកដាក់ ដែរឬទេ?

អត់ទេ! មានភាពខុសៗគ្នាជាច្រើនអំពីលក្ខណៈនៃ មនោសញ្ចេតនា រាងកាយ និង ការសិក្សា នៅក្នុងក្រុមក្មេងនីមួយៗ។ ក្មេងដែលមានអាយុតិចដែលនៅក្នុងថ្នាក់រួមបញ្ចូលគ្នា មានមនុស្សជាច្រើនដែលពួកគេអាចសុំឲ្យជួយ ហើយ ក្មេងដែលមានអាយុច្រើនដែល មានគំនិតចាស់ទុំ មានភាពជាអ្នកដឹកនាំ និង មានចំណេះដឹង ដែលពួកគេអាចយកជាគំរូ។

### វិធីដែលលោកអ្នកអាចជួយកូនដែលរៀននៅក្នុងថ្នាក់រួមបញ្ចូលគ្នា ឲ្យទទួលបានជោគជ័យ

លោកអ្នកមានលក្ខណៈសំខាន់ដល់ជោគជ័យរបស់កូនលោកអ្នក--នៅក្នុង ថ្នាក់រួមបញ្ចូលគ្នា ឬ ថ្នាក់ដែលមានកម្រិតដូចគ្នា។ ការដឹងព័ត៌មានច្រើនអំពី កូន និង ការអប់រំរបស់ពួកគេ លោកអ្នកអាច គាំទ្រ និង ជួយ កូនរបស់លោកអ្នកឲ្យមានជោគជ័យកាន់តែច្រើនឡើង។

### នេះជាវិធីខ្លះៗដែលលោកអ្នកអាចជួយកូនក្នុងការសិក្សារបស់ពួកគេ៖

អានព័ត៌មានមកពី គ្រូ និង សាលា របស់កូនលោកអ្នក ហើយក៏ប្រហែលជាមាននៅក្នុងវិបសៃរបស់សាលាផងដែរ។ ព័ត៌មានទាំងនេះអាចឲ្យលោកអ្នកដឹងនូវអ្វីៗដែលកើតមានឡើងនៅសាលា ហើយធ្វើឲ្យមានការងាយស្រួលដល់លោកអ្នក ក្នុងការនិយាយជាមួយកូនអំពីថ្ងៃរៀន។

ស្វែងយល់ថាតើកម្មវិធីនេះបានរៀបចំដើម្បីឲ្យត្រូវតាម សេចក្តីត្រូវការរបស់សិស្សនៅក្នុងថ្នាក់ទាំងមូល និង សេចក្តីត្រូវការរបស់ក្មេងម្នាក់ៗ យ៉ាងដូចម្តេច។

និយាយជាមួយកូនឲ្យបានទៀងទាត់អំពី បទពិសោធន៍នៅសាលា និង អំពីកិច្ចការសាលាដែលកូនយកមកផ្ទះ។ ត្រូវដឹងពីកម្មវិធីសិក្សាសម្រាប់កម្រិតថ្នាក់របស់កូនលោកអ្នក។ ព័ត៌មាននេះមាននៅក្នុងវិបសៃរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៖ http://webgui.phila.k12.pa.us/offices/c/curriculum/

និយាយជាមួយគ្រូរបស់កូនលោកអ្នកអំពីសេចក្តីត្រូវការក្នុងការសិក្សារបស់ក្មេងម្នាក់ៗ។ បើសិនជាលោកអ្នកមានសំណួរ ឬ ការបារម្ភ អ្វី សូមនិយាយជាមួយគ្រូ អំពីវិធីសាស្ត្រដែលពួកគេប្រើដើម្បីបង្រៀនកម្មវិធីសិក្សាតាមការបំបែកថ្នាក់។

ចូលរួមជាមួយសាលា។ ចូលរួមក្នុងយប់ផ្តល់ព័ត៌មានដល់មាតាបិតា និង កម្មវិធីផ្សេងៗនៅសាលា។ ស្ម័គ្រចិត្តជួយនៅសាលា បើសិនជាលោកអ្នកមានពេល។ ចូលរួមក្នុងអង្គប្រជុំរបស់ ក្រុមប្រឹក្សាសាលា។

**ការស្រាវជ្រាវអំពីថ្នាក់រួមបញ្ចូលគ្នា៖ តើថ្នាក់រួមបញ្ចូលគ្នា អាចដំណើរការបានដែរឬទេ?**

Dr. Joel Gajadharsingh (អតីតសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យ Saskatchewan) ជាអ្នកដឹកនាំក្នុងការស្រាវជ្រាវ ថ្នាក់រួមបញ្ចូលគ្នា នៅអាមេរិកខាងជើង។ ក្នុងឆ្នាំ១៩៩១ សមាគមផ្នែកអប់រំនៅប្រទេសកាណាដា បានរៀបរាប់ដោយសង្ខេបអំពីការស្រាវជ្រាវរបស់គាត់ ដែលបានរកឃើញ ដូចតទៅនេះ៖

១. ក្មេងដែលរៀនក្នុងថ្នាក់រួមបញ្ចូលគ្នា ទទួលការអប់រំល្អ ដូចគ្នា ឬ គ្រាន់បើជាង ថ្នាក់ដែលមានកម្រិតដូចគ្នា។

២. ក្មេងដែលរៀននៅក្នុងថ្នាក់ដែលមានកម្រិតខុសគ្នា កាន់តែមាន ឯករាជ្យភាព ជាអ្នកសិក្សាដែលមានការទទួលខុសត្រូវ ហើយបណ្តុះការទទួលខុសត្រូវនៅក្នុងសង្គមកាន់តែច្រើនឡើង។ ពួកគេក៏បណ្តុះទម្លាប់សិក្សាឲ្យកាន់តែប្រសើរឡើង និងកាន់តែចរិតវិជ្ជមាន ចំពោះសាលារៀន។

៣. គ្រូ៨៥% បានចាត់ទុកថា ជោគជ័យរបស់សិស្សានុសិស្សដែលរៀនក្នុងថ្នាក់លាយគ្នាមានកម្រិត ស្មើគ្នា ឬ លើសពី ជោគជ័យរបស់សិស្សដែលរៀនក្នុងថ្នាក់ដែលមានកម្រិតដូចគ្នា ចំពោះថ្នាក់ អក្សរសិល្ប៍ គណិតវិទ្យា វិទ្យាសាស្ត្រ និង សង្គមវិទ្យា។